**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករមូលបត្រកម្ពុជា** | **និយ័តករទូរគមនាគមន៍កម្ពុជា**

# សេចក្តីថ្លែងការណ៍រួម
# រវាង
# និយ័តករមូលបត្រកម្ពុជា និង និយ័តករទូរគមនាគមន៍កម្ពុជា

នាពេលកន្លងមកនេះ និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) និងនិយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) បានពិនិត្យឃើញថាមានការផ្សព្វផ្សាយអំពីផលិតផល និងសេវាកម្មពាក់ព័ន្ធនឹងមូលបត្រ ដែលគ្មានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី ន.ម.ក. តាមមធ្យោបាយទូរគមនាគមន៍ផ្សេងៗដូចជា គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម និងមធ្យោបាយទំនាក់ទំនងផ្សេងទៀត ក្នុងគោលបំណងទាក់ទាញសាធារណជនឱ្យដាក់ប្រាក់វិនិយោគ ឬធ្វើប្រតិបត្តិការផ្ញួញផ្សរដែលខុសច្បាប់  ដែលនាំឱ្យខាតបង់ថវិកា និងទ្រព្យសម្បត្តិ។ គេហទំព័រ ឬបណ្តាញទំនាក់ទំនងសង្គមមួយចំនួនមានប្រភពនៅក្រៅប្រទេសដែលធ្វើឱ្យ ន.ម.ក. ពិបាកនឹងគ្រប់គ្រង ចំណែកគេហទំព័រ ឬមធ្យោបាយទូរគមនាគមន៍មួយចំនួនទៀត ត្រូវបានបង្កើតឡើងដោយក្លែងបន្លំ តាមរយៈការប្រើប្រាស់ឈ្មោះ និងរូបភាពរបស់ថ្នាក់ដឹកនាំស្ថាប័ន ឬក្រុមហ៊ុនផ្សេងៗដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាត ដើម្បីទាក់ទាញសាធារណជនឱ្យដាក់ប្រាក់វិនិយោគ ឬធ្វើប្រតិបត្តិការជាមួយ ទោះបីជាមានវិធានការ និងចំណាត់ការផ្លូវច្បាប់ជាច្រើនត្រូវបានធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចក៏ដោយ។ សកម្មភាពទាំងនេះ បានធ្វើឱ្យសាធារណជនមានការភាន់ច្រឡំជាមួយក្រុមហ៊ុនមានអាជ្ញាបណ្ណ ឬការអនុញ្ញាតត្រឹមត្រូវ ប៉ះពាល់ដល់កិត្តិយសរបស់ថ្នាក់ដឹកនាំស្ថាប័ន បង្ករការខាតដល់បរិយាកាសវិនិយោគនៅកម្ពុជា និងប៉ះពាល់ដល់ជំនឿទុកចិត្តរបស់វិនិយោគិនក្នុងវិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងន័យនេះ ន.ម.ក. និង ន.ទ.ក. នឹងសហការគ្នាយ៉ាងជិតស្និទ្ធលើការចាត់វិធានការបិទខ្ទប់គេហទំព័រមាតិកានៅក្នុងបណ្តាញទំនាក់ទំនងសង្គម និងមាតិកាផ្សព្វផ្សាយលើមធ្យោបាយទូរគមនាគមន៍ផ្សេងៗ ដែលធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្រដោយគ្មានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី ន.ម.ក. សំដៅរួមគ្នាបង្ការ និងទប់ស្កាត់តាមយន្តការច្បាប់ ដែលមានជាធរមាន។ ជាមួយគ្នានេះ សាធារណជនអាចស្វែងរកបញ្ជីបច្ចុប្បន្នភាពនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី ន.ម.ក. រួមទាំងគេហទំព័រផ្លូវការរបស់ក្រុមហ៊ុនទាំងនេះ តាមរយៈគេហទំព័ររបស់ ន.ម.ក. www.serc.gov.kh ឬតាមរយៈ QR Code ខាងក្រោម។

**ន.ម.ក.** និង **ន.ខ.ក.** សូមក្រើនរំលឹក និងអំពាវនាវដល់សាធារណជនទាំងអស់មេត្តាមាន**ការប្រុងប្រយ័ត្នខ្ពស់បំផុត** ចំពោះការធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្រជាមួយគេហទំព័រ បណ្ដាញទំនាក់ទំនងសង្គម និងមធ្យោបាយខ្វរគមនាគមន៍ផ្សេងទៀត ដែលផ្សព្វផ្សាយអំពីផលិតផល និងសេវាកម្មពាក់ព័ន្ធនឹងមូលបត្រ ដែលគ្មានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី **ន.ម.ក.**។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់អនុវត្តតាមស្មារតីនៃសេចក្ដីថ្លែងការណ៍នេះ ឱ្យបានខ្ជាប់ខ្ជួន។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤

**និយ័តករមូលបត្រកម្ពុជា** **និយ័តករទូរគមនាគមន៍កម្ពុជា**

*QR Code*

*គេហទំព័រផ្លូវការ ន.ម.ក.*